UW Medicine
DIGITAL HEALTH

# ការជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិច (Your Telemedicine Visit)

*តើការជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិចជាអ្វី របៀបដែលវាដំណើរការ និងរបៀបបញ្ចូលកម្មវិធីឧបករណ៍របស់អ្នក*

## មាតិកា

***អំពីការជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច Telemedicine Visits) (ទំព័រ 2)***

***អំពីហ្សូម (Zoom) (ទំព័រ 2)***

***សុវត្ថិភាព និងសិទ្ធិឯកជនភាពរបស់អ្នក (ទំព័រ 2)***

***របៀបរៀបចំសម្រាប់ការជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច (Telemedicine Visits) (ទំព័រ 2)***

***ប្រសិនបើលោកអ្នកមានសំណួរ (ទំព័រ 2)***

***ការប្រើប្រាស់ស្មាតហ្វូន ឬថេបប្លេតសម្រាប់ការជួបរបស់អ្នក (ទំព័រ 3-8)***

***ការប្រើប្រាស់កុំព្យូទ័រ ឬថេបប្លេតសម្រាប់ការជួបរបស់អ្នក (ទំព័រ 9-12)***


UW Medicine Patient Care Services
1959 N.E. Pacific St., Seattle, WA 98195



*នៅអំឡុងពេលការជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច លោកអ្នក និងអ្នកផ្ដល់សេវាកម្មរបស់អ្នក អាចមើលឃើញគ្នាទៅវិញទៅមកនៅលើកុំព្យូទ័រ ថេបប្លេត ឬស្មាតហ្វូនរបស់អ្នក។*

## អំពីការជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិច

ការជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិចគឺជាមធ្យោបាយមួយដើម្បីទទួលបានការថែទាំសុខភាពដែលលោកអ្នកត្រូវការ នៅពេលលោកអ្នកមិនអាចមកគ្លីនិក ដើម្បីជួបអ្នកផ្ដល់សេវាកម្មរបស់អ្នក។ ការជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិច នៅមណ្ឌលសុខភាព UW Medicine ប្រើប្រាស់សេវាកម្មវីដេអូហៅថាហ្សូម (Zoom)។

## អំពីហ្សូម (Zoom)

ហ្សូម (Zoom) អនុញ្ញាតឱ្យលោកអ្នកមើលឃើញ និងនិយាយជាមួយនរណាម្នាក់ពីចម្ងាយ។ វាដំណើរការលើកុំព្យូទ័រ ថេបប្លេត ឬស្មាតហ្វូន។

ហ្សូម (Zoom) ប្រើឥតគិតថ្លៃ។ លោកអ្នកមិនចាំបាច់បង្កើតគណនីទេ។

## សុវត្ថិភាព និងសិទ្ធិឯកជនភាពរបស់អ្នក

ការជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិច នឹងមានសុវត្ថិភាព សិទ្ធិឯកជនភាព និងមានការការពារ។ រូបថត និងសម្លេងរបស់អ្នក នឹងមិនត្រូវបានថត ឬរក្សាទុកទេ។ ព័ត៌មានទាំងអស់របស់អ្នកត្រូវបានការពារ ដូចជាបើលោកអ្នកកំពុងជួបជាមួយអ្នកផ្ដល់

សេវាកម្មថែទាំសុខភាពរបស់អ្នកនៅក្នុងគ្លីនិក។ ហ្សូម (Zoom) គោរពតាមច្បាប់ស្ដីពីភាពអាចបត់បែនបាននៃការធានារ៉ាប់រងសុខភាព និងការទទួលខុសត្រូវ (Health Insurance Portability and Accountability Act, HIPAA) ដែលការពារសិទ្ធិឯកជនភាពសុខភាពរបស់អ្នក។

## របៀបរៀបចំសម្រាប់ការជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច

- មុនពេលលោកអ្នកជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិចលើកដំបូង សូមបញ្ចូលកម្មវិធីហ្សូម (Zoom) នៅក្នុងឧបករណ៍របស់អ្នក។
- លោកអ្នកត្រូវមាន៖
  - កុំព្យូទ័រ ថេបប្លេត ឬស្មាតហ្វូនដែលមានកាមេរ៉ាដែលមើលឃើញមុខលោកអ្នក ដូច្នេះអ្នកផ្ដល់សេវាកម្មរបស់អ្នកអាចមើលឃើញលោកអ្នក។
  - ការភ្ជាប់អ៊ីនធឺណិត
- ប្រសិនបើលោកអ្នកចង់ពិនិត្យមើលការតភ្ជាប់អ៊ីនធឺណិតរបស់អ្នក សូមចូលទៅ *zoom.us/test* ដើម្បីចូលរួមកិច្ចប្រជុំសាកល្បង។

## ប្រសិនបើលោកអ្នកមានសំណួរ

- ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការបញ្ចូលកម្មវិធីហ្សូម (Zoom) សូមហៅទូរស័ព្ទទៅផ្នែកសេវាកម្មរបស់យើងតាមលេខ **206.520.5100.**
- ដើម្បីស្វែងយល់បន្ថែមអំពីការជួបអ្នកផ្ដល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច (Telemedicine) នៅមណ្ឌលសុខភាព UW Medicine សូមចូលទៅគេហទំព័ររបស់យើង៖ ***www.uwmedicine.org/virtual-care***

# ការប្រើប្រាស់ស្មាតហ្វូន ឬថេបប្លេតសម្រាប់ការជួបរបស់អ្នក

## មុនពេលលោកអ្នកទៅជួប Telemedicine Visit លើកដំបូង

### ជំហាន 1: ទាញយកកម្មវិធី Zoom។

- ទាញយកកម្មវិធី Zoom Cloud Meeting ពី Apple App Store ឬតាម Google Play។ (ធ្វើបច្ចុប្បន្នភាព បើមានការណែនាំ។ ) ប្រសិនបើលោកអ្នកប្រើឧបករណ៍ដូចគ្នានឹងការជួបនាពេលអនាគត លោកអ្នកមិនត្រូវធ្វើជំហាននេះម្ដងទៀតទេ។ ប្រសិនបើលោកអ្នកប្រើឧបករណ៍ផ្សេង លោកអ្នកនឹងត្រូវការបញ្ចូលម្ដងទៀត។

- ប្រសិនបើលោកអ្នកចង់ឃើញរបារឧបករណ៍ពិនិត្យមើលកិច្ចប្រជុំ Zoom គ្រប់ពេល៖
  1. ចុចលើរូបតំណាងការកំណត់ (ឧបករណ៍ gear)។
  2. ចុចលើ "កិច្ចប្រជុំ" ("Meetings")។

3. បើក "បង្ហាញការពិនិត្យមើលកិច្ចប្រជុំជានិច្ច។" (“Always show meeting controls.”)




## មុនពេលអ្នកផ្តល់សេវាកម្មរបស់អ្នកចូលរួមកិច្ចប្រជុំ

### ជំហាន 2: បង្កើតកន្លែងស្ងាត់សម្រាប់ការជួបរបស់អ្នក។

- ចំណាយពេលរបស់អ្នកយ៉ាងតិច 15 នាទី ដើម្បីរៀបចំ និងភ្ជាប់ទំនាក់ទំនង។
- សូមប្រាកដថាឧបករណ៍របស់អ្នកបានដោតចូល ឬសាកថ្មពេញ។
- អង្គុយកន្លែងស្ងៀមស្ងាត់ដែលមានពន្លឺល្អ។
- ប្រសិនបើលោកអ្នកអាច សូមស្វែងរកកន្លែងឯកជនមួយសម្រាប់ការជួបរបស់អ្នក។ ប្រសិនបើមានមនុស្សផ្សេងទៀតនៅក្បែរនោះ លោកអ្នកអាចប្រើកាសសម្រាប់ភាពឯកជន។

### ជំហាន 3: ចាប់ផ្តើមហ្សូម (Start Zoom)។

***A. ប្រសិនបើលោកអ្នកមានកម្មវិធី MyChart***

- សម្រាប់ iPhone ឬ iPad, សូមបិទកម្មវិធីទប់ស្កាត់ប៉បអាប់ប្លុកឃ័រ (disable pop-up blockers):
  1. ចុចលើ “ការកំណត់” ("Settings")
  2. ចុចលើ “សាហ្វារី” (“Safari”)
  3. បិទ “ប្លុកប៉បអាប់” (“Block Pop-ups”)




- សម្រាប់ Android, សូមបិទកម្មវិធីទប់ស្កាត់ប៉បអាប់ប្លកឃ័រ (disable pop-up blockers):
  1. ចុចលើកម្មវិធី “ក្រូម” (“Chrome”)
  2. ចុចលើចំណុចបញ្ឈរចំនួន 3 នៅខាងស្តាំខាងលើ
  3. ចុច “ការកំណត់” ("Settings")
  4. ចុច “ការកំណត់គេហទំព័រ” ("Site Settings")
  5. ចុច "ប៉បអាប់ និងបញ្ជូនបន្ត” (“Pop-ups and redirect”)
  6. បើក "ប៉បអាប់ និងបញ្ជូនបន្ត” (“Pop-ups and redirect”)


UW Medicine Patient Care Services
1959 N.E. Pacific St., Seattle, WA 98195





UW Medicine Patient Care Services
1959 N.E. Pacific St., Seattle, WA 98195

- ចូលទៅកម្មវិធី MyChart ហើយចូលប្រើ (log in)។ ធ្វើបច្ចុប្បន្នភាពកម្មវិធី MyChart ប្រសិនបើមានការណែនាំ។
    1. ជ្រើសរើសជម្រើស "ចាប់ផ្តើមជួបតាមវីដេអូរបស់អ្នក" ("Begin your video visit.")
    2. ជ្រើសរើស "ចាប់ផ្តើមជួប" ("Begin Visit")។ វានឹងចាប់ផ្តើមកម្មវិធីហ្សូម Zoom។




- Zoom នឹងសួររកឈ្មោះរបស់អ្នក។ បញ្ចូលឈ្មោះ និងនាមត្រកូលរបស់អ្នក។
- លោកអ្នកអាចដាក់នៅក្នុង "បន្ទប់រង់ចាំ" ("Waiting Room") នៅខណៈពេលអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកត្រៀមខ្លួនរួចរាល់ដើម្បីចូលរួម។ វាអាចចំណាយពេលពីរបីនាទីសម្រាប់អ្នកផ្តល់សេវាកម្មដើម្បីចូលរួម។ សូមរក្សាស្ថិតនៅអនឡាញ។ អរគុណលោកអ្នកចំពោះការអត់ធ្មត់របស់អ្នក។

### *B. ប្រសិនបើលោកអ្នកមិនមានកម្មវិធី MyChart*

- មុនពេលលោកអ្នកជួប យើងនឹងផ្ញើជូនលោកអ្នកនូវអត្ថបទមួយដែលមានតំណភ្ជាប់ទៅកាន់ទូរស័ព្ទរបស់អ្នក។
- សូមធ្វើតាមតំណភ្ជាប់នេះ ដើម្បីចូលទៅគេហទំព័រកម្មវិធីហ្សូម Zoom។
- ជ្រើសរើសប្រើកម្មវិធី Zoom Cloud ដើម្បីបើកតំណភ្ជាប់នេះ (ប្រសិនបើមានការណែនាំ)។
- នឹងសួររកឈ្មោះរបស់អ្នក។ បញ្ចូលឈ្មោះ និងនាមត្រកូលរបស់អ្នក។
- លោកអ្នកអាចដាក់នៅក្នុង "បន្ទប់រង់ចាំ" (“Waiting Room”) នៅខណៈពេលអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកត្រៀមខ្លួនរួចរាល់ដើម្បីចូលរួម។ វាអាចចំណាយពេលពីរបីនាទីសម្រាប់អ្នកផ្តល់សេវាកម្មដើម្បីចូលរួម។ សូមរក្សាស្ថិតនៅអនឡាញ។ អរគុណលោកអ្នកចំពោះការអត់ធ្មត់របស់អ្នក។

## នៅពេលអ្នកផ្តល់សេវាកម្មរបស់អ្នកចូលរួមកិច្ចប្រជុំ

### ជំហាន 4: ភ្ជាប់អូឌីយ៉ូឬសម្លេង។

យើងណែនាំឱ្យប្រើអ៊ីនធឺណិត ឬឧបករណ៍អូឌីយ៉ូឬសម្លេង៖

- សម្រាប់ iPhone សូមជ្រើសរើស “ហៅទូរស័ព្ទដោយប្រើអូឌីយ៉ូឬសម្លេងអ៊ីនធឺណិត” (“Call using Internet Audio”)




- សម្រាប់ Android សូមជ្រើសរើស “ហៅទូរស័ព្ទតាមឧបករណ៍អូឌីយ៉ូឬសម្លេង” (“Call via Device Audio”)




- ប្រសិនបើលោកអ្នកជ្រើសរើស "ចុចចូល” (“Dial in”) នោះ បញ្ជីលេខនឹងបង្ហាញឡើង។ ជ្រើសរើសលេខដើម្បីហៅទូរស័ព្ទ។ (អ្នកអាចប្រើលេខណាមួយក្នុងចំណោមលេខនេះ ) ស្មាតហ្វូន ឬថេបប្លេតរបស់អ្នកនឹងបញ្ចូលកិច្ចប្រជុំ និងលេខសម្គាល់អ្នកចូលរួម ID សម្រាប់អ្នក។

### ជំហាន 5: បើកកាមេរ៉ា និងមីក្រូហ្វូន។

- លោកអ្នកអាចត្រូវការចុចអេក្រង់របស់អ្នក ដើម្បីឱ្យរបារឧបករណ៍បង្ហាញ។
- ត្រូវប្រាកដថាមីក្រូហ្វូន និងឧបករណ៍បំពងសម្លេងរបស់អ្នកមិនត្រូវបិទសម្លេងទេ។ លោកអ្នកអាចត្រូវការចុច "បើកសម្លេង" ("Unmute") នៅលើរបារ។
- សូមប្រាកដថាវីដេអូរបស់អ្នក ត្រូវបានចាប់ផ្តើម។ លោកអ្នកអាចត្រូវការចុច "ចាប់ផ្តើមវិដេអូ" ("Start Video") នៅលើរបារ។




*និមិត្តសញ្ញាសម្រាប់ "បិទសម្លេង" ("Mute") និង "ចាប់ផ្តើមវីដេអូ" ("Start Video") នៅលើរបារ។*

### ជំហាន 6: ចាប់ផ្តើមជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិច

ឥឡូវនេះ អ្នកត្រៀមខ្លួនរួចរាល់ហើយ ដើម្បីចាប់ផ្តើមដំណើរការជួបរបស់អ្នក។

ប្រសិនបើអ្នកផ្តល់សេវាកម្មរបស់អ្នក មានបញ្ហាមើលឃើញ ឬស្តាប់ឮអ្នក ពួកគេអាចហៅមកអ្នកតាមលេខដែលអ្នកបានផ្តល់ជូននៅពេលចាប់ផ្តើមកិច្ចប្រជុំរបស់អ្នក។ ប្រសិនបើលោកអ្នកកំពុងប្រើថេបប្លេត សូមទុកទូរស័ព្ទរបស់អ្នកនៅក្បែរ ក្នុងករណីត្រូវការចាំបាច់។

## ការប្រើប្រាស់កុំព្យូទ័រសម្រាប់ការជួបរបស់អ្នក

ការណែនាំទាំងនេះ សម្រាប់អ្នកជំងឺដែលមានគណនីកម្មវិធី MyChart។

**ប្រសិនបើលោកអ្នកមិនមានគណនីកម្មវិធី MyChart:**

- សូមអនុវត្តតាមការណែនាំនៅទំព័រទី 3 ក្រោម "ការប្រើប្រាស់ស្មាតហ្វូន ឬថេបប្លេតសម្រាប់ការជួបរបស់អ្នក។"
- នៅពេលលោកអ្នកឈានដល់ជំហានទី 3 សូមធ្វើតាមការណែនាំនៅទំព័រ 6 ក្រោម "B។ ប្រសិនបើលោកអ្នកមិនមានកម្មវិធី MyChart ។"

## មុនពេលលោកអ្នកទៅជួប Telemedicine Visit លើកដំបូង

### ជំហាន 1: ទាញយក "អតិថិជន Zoom សម្រាប់កិច្ចប្រជុំ" ("Zoom Client for Meetings.")

- សូមចូលទៅ *zoom.us/download*. ចុចលើប៊ូតុង "ទាញយក" ("Download" នៅក្រោម "អតិថិជន Zoom សម្រាប់កិច្ចប្រជុំ" ("Zoom Client for Meetings.")
- ជ្រើសរើសដើម្បីដំណើរការ Zoom (ប្រសិនបើមានការណែនាំ) ។

## មុនពេលអ្នកផ្តល់សេវាកម្មរបស់អ្នកចូលរួមកិច្ចប្រជុំ

### ជំហាន 2: បង្កើតកន្លែងស្ងាត់សម្រាប់ការជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច។

- ចំណាយពេលរបស់អ្នកយ៉ាងតិច 15 នាទី ដើម្បីរៀបចំ និងភ្ជាប់ទំនាក់ទំនង។
- សូមប្រាកដថាឧបករណ៍របស់អ្នកបានដោតចូល ឬសាកថ្មពេញ។
- អង្គុយកន្លែងស្ងៀមស្ងាត់ដែលមានពន្លឺល្អ។
- ប្រសិនបើលោកអ្នកអាច សូមស្វែងរកកន្លែងឯកជនមួយសម្រាប់ការជួបរបស់អ្នក។ ប្រសិនបើមានមនុស្សផ្សេងទៀតនៅក្បែរនោះ លោកអ្នកអាចប្រើកាសសម្រាប់ភាពឯកជន។

### ជំហាន 3: ចាប់ផ្តើម Zoom (ជាមួយកម្មវិធី MyChart)

- សូមចូលទៅ *mychart.uwmedicine.org*.
- សូមចូលប្រើ (Log into) កម្មវិធី MyChart.
  1. ជ្រើសរើសជម្រើស "ចាប់ផ្តើមជួបតាមវីដេអូរបស់អ្នក" ("Begin your video visit.")
  2. ជ្រើសរើស "ចាប់ផ្តើមជួប" ("Begin Visit")។ វានឹងចាប់ផ្តើមកម្មវិធីហ្សូម Zoom។







- Zoom នឹងសួររកឈ្មោះរបស់អ្នក។ បញ្ចូលឈ្មោះ និងនាមត្រកូលរបស់អ្នក។

លោកអ្នកអាចដាក់នៅក្នុង "បន្ទប់រង់ចាំ" ("Waiting Room") នៅខណៈពេលអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកត្រៀមខ្លួនរួចរាល់ដើម្បីចូលរួម។ វាអាចចំណាយពេលពីរបីនាទីសម្រាប់អ្នកផ្តល់សេវាកម្មដើម្បីចូលរួម។ សូមរក្សាស្ថិតនៅអនឡាញ។ អរគុណលោកអ្នកចំពោះការអត់ធ្មត់របស់អ្នក។

## នៅពេលអ្នកផ្តល់សេវាកម្មរបស់អ្នកចូលរួមកិច្ចប្រជុំ

### ជំហាន 4: ភ្ជាប់អូឌីយ៉ូឬសម្លេង។

- យើងណែនាំឱ្យប្រើមីក្រូហ្វូន និងឧបករណ៍បំពងសម្លេងកុំព្យូទ័ររបស់អ្នក សម្រាប់អូឌីយ៉ូឬសម្លេង។ ជ្រើសរើស "អូឌីយ៉ូកុំព្យូទ័រ" ("Computer Audio") ហើយចុច "ចូលរួមជាមួយអូឌីយ៉ូកុំព្យូទ័រ" ("Join with Computer Audio")។




- ប្រសិនបើអ្នកកំពុងប្រើទូរស័ព្ទរបស់អ្នកសម្រាប់អូឌីយ៉ូឬសម្លេង សូមជ្រើសរើស "ការហៅទូរស័ព្ទ" (Phone Call,") ហើយបញ្ជីលេខនឹងបង្ហាញឡើង៖

  1. ជ្រើសរើសលេខណាមួយពីផ្នែក "ចុច" ("Dial") ដើម្បីហៅទូរស័ព្ទ។
  2. លោកអ្នកនឹងត្រូវបានស្នើសុំឱ្យបញ្ចូលលេខសម្គាល់កិច្ចប្រជុំ។ បញ្ចូលលេខដែលបានរាយបញ្ជីក្នុងផ្នែក "លេខសម្គាល់កិច្ចប្រជុំ" ("Meeting ID") បន្ទាប់មកចុច #.
  3. លោកអ្នកនឹងត្រូវបានស្នើសុំឱ្យបញ្ចូលលេខសម្គាល់ ID អ្នកចូលរួម។។ បញ្ចូលលេខដែលបានរាយបញ្ជីក្នុងផ្នែក "លេខសម្គាល់អ្នកចូល

រួម" (“Participant ID” ) បន្ទាប់មកចុច #. ឬគ្រាន់តែចុច # ដើម្បីបន្តដំណើរការ។




## ជំហាន 5: បើកកាមេរ៉ា និងមីក្រូហ្វូន។

- ចុចខាងក្នុងកម្មវិធីវីនដូហ្សូម (Zoom window) សម្រាប់របារដើម្បីបង្ហាញឡើង។
- ត្រូវប្រាកដថាមីក្រូហ្វូន និងឧបករណ៍បំពងសម្លេងរបស់អ្នកមិនត្រូវបិទសម្លេងទេ។ លោកអ្នកអាចត្រូវការចុច “បើកសម្លេង” (“Unmute”) នៅលើរបារ។
- សូមប្រាកដថាវីដេអូរបស់អ្នក ត្រូវបានចាប់ផ្តើម។ លោកអ្នកអាចត្រូវការចុច “ចាប់ផ្តើមវីដេអូ” (“Start Video”) នៅលើរបារ។




*និមិត្តសញ្ញាសម្រាប់ "បិទសម្លេង" (“Mute”) និង "ចាប់ផ្តើមវីដេអូ" (“Start Video”) នៅលើរបារហ្សូម Zoom។*

## ជំហាន 6: ចាប់ផ្តើមជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកតាមអេឡិចត្រូនិច

ឥឡូវនេះ អ្នកត្រៀមខ្លួនរួចរាល់ហើយ ដើម្បីចាប់ផ្តើមដំណើរការជួបរបស់អ្នក។

ប្រសិនបើអ្នកផ្តល់សេវាកម្មរបស់អ្នក មានបញ្ហាមើលឃើញ ឬស្តាប់ឮអ្នក ពួកគេអាចហៅមកអ្នកតាមលេខដែលអ្នកបានផ្តល់ជូននៅពេលលោកអ្នកកំណត់ការជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច។ សូមទុកទូរស័ព្ទរបស់អ្នកនៅក្បែរ ក្នុងករណីត្រូវការចាំបាច់។

## មានសំណួរ?

សំណួររបស់អ្នកមានសារៈសំខាន់ណាស់។ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិត ឬអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក ប្រសិនបើលោកអ្នកមានសំណួរ ឬបញ្ហាជារឿង។

- ដើម្បីស្វែងយល់បន្ថែមអំពីការជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពតាមអេឡិចត្រូនិច (Telemedicine) នៅមណ្ឌលសុខភាព UW Medicine សូមចូលទៅគេហទំព័ររបស់យើង៖ ***www.uwmedicine.org/virtual-care***
- ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការបញ្ចូលកម្មវិធីហ្សូម (Zoom) សូមហៅទូរស័ព្ទទៅការិយាល័យសេវាកម្មរបស់យើងតាមលេខ **206.520.5100**.

© UW Medicine
Published PFES: 2021
Clinician Review: 03/2021
Reprints on Health Online: https://healthonline.washington.edu



UW Medicine Patient Care Services
1959 N.E. Pacific St., Seattle, WA 98195